**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible]...សហវ.ប្រក

ថ្ងៃព្រហស្បតិ៍ ៥ កើត ខែអាសាឍ ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២០

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ÷** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍ដោះស្រាយបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងឆ្នាំជាបន្តបន្ទាប់នៅក្រសួងអប់រំ យុវជន និងកីឡា ។

**យោង÷** លិខិតលេខ១៩៨២ អយក.ហវ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ជ្រាបថា ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តថវិកានៅក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០២០ និងឆ្នាំជាបន្តបន្ទាប់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានពិនិត្យនិងសម្រេចដូចខាងក្រោម ÷

១- អនុញ្ញាតបើកផ្តល់ប្រាក់អាហារូបករណ៍ជូនសិស្សក្រីក្រជួបការលំបាកនៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅ ចំនួន ៣ លើក តាមប្រតិទិនដូចខាងក្រោម ÷

- លើកទី ១ ÷ នៅដើមខែវិច្ឆិកា ក្នុងត្រីមាសទី ៤ នៃឆ្នាំថវិកាចាស់ (ក្នុងអំឡុងពេលបើកបវេសនកាលដំបូង)
- លើកទី ២ ÷ នៅដើមខែមីនា ក្នុងត្រីមាសទី ១ នៃឆ្នាំថវិកាថ្មី, និង
- លើកទី ៣ ÷ នៅដើមខែកក្កដា ក្នុងត្រីមាសទី ៣ នៃឆ្នាំថវិកាថ្មី ។

ប្រតិទិននៃការផ្តល់ថវិកាអាហារូបករណ៍នេះ ត្រូវអនុវត្តចាប់ពីឆ្នាំសិក្សា ២០២០-២០២១ តទៅ ។

២- ចំពោះការស្នើបន្ថែមសិទ្ធអំណាចជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យសម្រេចផ្តល់ទិដ្ឋាការលើលិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់លើមុខចំណាយចំនួនពីរទៀត រួមមាន ការបើកផ្តល់អាហារូបករណ៍សម្រាប់ទ្រទ្រង់ជីវភាពនិស្សិតពិការ និងចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ÷ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យមើលលទ្ធភាពក្នុងការផ្តល់សិទ្ធបន្ថែមជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌរួមនៃការត្រួតពិនិត្យហិរញ្ញវត្ថុនៅគ្រប់ក្រសួង ស្ថាប័ន ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

៣- អនុញ្ញាតឱ្យសាលាគរុកោសល្យ និងវិក្រឹតការខេត្ត, មជ្ឈមណ្ឌលគរុកោសល្យខេត្ត, វិទ្យាល័យអប់រំពិសេស និងគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលអនុវត្តកម្មវិធីបង្រៀន និងរៀនពេញមួយថ្ងៃ ប្រើប្រាស់អនុគណនី ចំនួន ៤ សម្រាប់អនុវត្តថវិកាក្នុងក្របខ័ណ្ឌដំណើរការគ្រឹះស្ថានសាមី ដោយយកលំនាំតាមការអនុវត្តថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ (SOF) ។ អនុគណនីទាំង ៤ នោះគឺ ÷

- អនុគណនី ៦០០២៨ (សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ)
- អនុគណនី ៦០០៥៨ (សម្ភារៈតូចតាច សង្ហារិម និងសម្ភារៈបរិក្ខាផ្សេងៗ)
- អនុគណនី ៦១០៥៨ (ការថែទាំនិងជួសជុលផ្សេងៗ) និង
- អនុគណនី ៦១១០៨ (ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយផ្សេងៗ) ។

ចំណែកមុខសញ្ញាចំណាយសម្រាប់កត់ត្រាចូលក្នុងអនុគណនីទាំង ៤ នេះ ត្រូវអនុវត្តតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលរៀនសាធារណៈ ។

៤- អនុញ្ញាតឱ្យក្រសួងអប់រំ យុវជន និងកីឡាប្រើប្រាស់អនុគណនី ៦២០២៨ (ជំនួយសង្គមផ្សេងៗ) សម្រាប់គ្រោងនិងកត់ត្រាចំណាយប្រាក់ឧបត្ថម្ភលើកទឹកចិត្តជូនគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ តាមអត្រាដែលមានក្នុងស្មារតីអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនតាមកម្មវិធីអប់រំក្រៅប្រព័ន្ធ ។

៥- អនុញ្ញាតជាគោលការណ៍ក្នុងការផ្តល់ថវិកាជូនវិទ្យាល័យអប់រំពិសេសចំនួន ៦០ លានរៀល ក្នុងមួយសាលា ក្នុងមួយឆ្នាំ សម្រាប់ដំណើរការសាលារៀន ។

៦- អនុញ្ញាតជាគោលការណ៍ក្នុងការផ្តល់ថវិកាជូនគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលអនុវត្តកម្មវិធីបង្រៀន និងរៀនពេញមួយថ្ងៃ ចំនួន ២០ លានរៀល ក្នុងមួយសាលា ក្នុងមួយឆ្នាំ សម្រាប់ដំណើរការសាលារៀន ។

៧- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំគ្រោងថវិកាក្នុងផែនការប្រចាំរបស់ខ្លួនក្នុងឆ្នាំ២០២០ សម្រាប់អនុវត្តចាប់ពីឆ្នាំ ២០២១ តទៅ សម្រាប់ចំណុចទី៣, ទី៤, ទី៥ និង ទី៦ ខាងលើ ។

៨- ចំពោះការស្នើសុំអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកទទួលបន្ទុករៀបចំការគ្រោងថវិកាប្រចាំឆ្នាំសម្រាប់ចំណាយវិនិយោគ (ជំពូក២១) ដូចលំនាំនៃចំណាយចរន្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡា ប្រើប្រាស់យន្តការ

របស់គណៈកម្មការអន្តរក្រសួង ដែលកំពុងត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលគម្រោងសាងសង់ និងកែលម្អអគារសិក្សា ទីចាត់ការ បណ្ណាល័យ អន្តេវាសិកដ្ឋាន និងហេដ្ឋារចនា-សម្ព័ន្ធនានាបម្រើឱ្យវិស័យអប់រំ និងកីឡា ជាពិសេសឈានទៅអនុលោមតាមអនុក្រឹត្យ/ប្រកាសស្តីពីនីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់គម្រោងវិនិយោគសាធារណៈ ហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់) ដែលនឹងត្រូវបានអនុម័តដាក់ឱ្យអនុវត្តជាធរមាននាពេលខាងមុខ ។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**<u>ចម្លងជូន ÷</u>**

-អគ្គនាយកដ្ឋានរតនាគារជាតិ

-ឯកសារ-កាលប្បវត្តិ